ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៣

# អនុក្រឹត្យលេខ ១៥ អនក្រ

# ស្តីពីការបង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

# ហៅកាត់ « ក.អ.ក »

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងការងារចាំបាច់ របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ :** បង្កើតក្រុមប្រឹក្សាជាតិមួយ មានឈ្មោះថា " ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា " ដែលហៅកាត់ថា " ក.អ.ក " ហើយមានសមាសភាពដូចតទៅ :

១. សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ ជាប្រធាន

២. ឯកឧត្តមទេសរដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ជាអនុប្រធាន

៣. ព្រះអង្គម្ចាស់ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

៤. ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសាធារណៈការនិងដឹកជញ្ជូន ជាសមាជិក

៥. ឯកឧត្តមទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការវប្បធម៌វិចិត្រសិល្បៈ រៀបចំដែនដី និងនគរូបនីយកម្ម ជាសមាជិក

៦. ឯកឧត្តមទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

៧. ឯកឧត្តមរដ្ឋមន្ត្រីក្រសួងផែនការ ជាសមាជិក

ព្រមជាមួយនេះ "ក.អ.ក" មានអគ្គលេខាធិការមួយរូប ដែលមានភារកិច្ចជួយសំរបសំរួលការងារទូទៅ ។

**ប្រការ ២ :** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវបង្កើតគណៈកម្មាធិការជាតិពីរ សំរាប់ជាជំនួយការ :

១. គណៈកម្មាធិការជាតិ សំរាប់ទីតិសម្បទា និងអភិវឌ្ឍន៍ហៅកាត់ " គជនា "

២. គណៈកម្មាធិការជាតិ វិនិយោគ ហៅកាត់ " គជវិ "

**ប្រការ ៣ :** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ :

១. លើកលំដាប់អទិភាពនៃតំរូវការរបស់ប្រទេសជាតិ ក្នុងការស្តារនិងអភិវឌ្ឍន៍ក្នុងពេលបច្ចុប្បន្នជាបន្ទាន់ និងសំរាប់រយៈពេលខ្លី រយៈពេលមធ្យម រយៈពេលវែង ដើម្បីបង្កើតនូវទស្សនាទាននិងកម្មវិធីរួមមួយ អំពីការងារស្តារ និង អភិវឌ្ឍន៍កម្ពុជា ។ កម្មវិធីនេះ ត្រូវមានលក្ខណៈជាប្រព័ន្ធប្រទាក់ក្រឡា និងស៊ីសង្វាក់គ្នា ។

២. តំរង់ទិសក្នុងបែងចែក និងផ្គត់ផ្គង់ធនធាននៅក្នុងប្រទេស និងធនធានដែលបានមកពីក្រៅប្រទេស ដើម្បីកិច្ចការស្តារ និងអភិវឌ្ឍន៍កម្ពុជា ។

៣. គ្រប់គ្រងនិងសំរបសំរួលកិច្ចការទទួលជំនួយបរទេស ដែលក្នុងនេះមានជំនួយទ្វេភាគី ពហុភាគី អង្គការអន្តរជាតិ និងជំនួយអង្គការមិនមែនរដ្ឋាភិបាលនានា អោយស្របតាមសេចក្តីត្រូវការរបស់ប្រទេស ព្រមទាំងអោយស្របជាមួយកម្មវិធីស្តារ និងអភិវឌ្ឍន៍កម្ពុជា ។

៤. រៀបចំចងក្រងឯកសារច្បាប់ និងលិខិតបទដ្ឋាននានាដែលទាក់ទងនិងការងារវិនិយោគ ស្តារនិងអភិវឌ្ឍន៍ សំរាប់ផ្សព្វផ្សាយដល់អ្នកវិនិយោគជាតិ និងអន្តរជាតិ និងក្រសួងស្ថាប័ននានាដែលពាក់ព័ន្ធ ។

៥. ជួយបង្កលក្ខណៈងាយស្រួល និងផ្តល់ពត៌មានដល់អ្នកវិនិយោគក្នុងវិស័យផ្សេងៗ អំពីអង្គភាពនានានៅប្រទេសកម្ពុជា ដែលត្រូវធ្វើទំនាក់ទំនងនិងអំពីច្បាប់វិនិយោគបែបបទដែលត្រូវធ្វើ ។ ជួយផ្តល់មតិដល់ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងក្រុង ដើម្បីសហការបានល្អជាមួយអ្នកវិយោគ ។

៦. ទទួលបន្ទុកសំរបសំរួលរវាងអ្នកវិនិយោគ ជាមួយបណ្តាក្រសួង ស្ថាប័ន រាជធានី ខេត្ត និងក្រុង ដើម្បីសហការបានល្អជាមួយអ្នកវិនិយោគ ។

៧. ធ្វើរបាយការណ៍បូកសរុបសភាពការណ៍អនុវត្តន៍ការងារវិនិយោគស្តារ និងអភិវឌ្ឍន៍លើគ្រប់វិស័យជូនគណៈរដ្ឋមន្ត្រីតាមកាលកំណត់ ។

**ប្រការ ៤ :** សមត្ថកិច្ចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាគ្របដណ្តប់លើផ្នែកដូចតទៅ :

១. ស្ពាននិងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសំរាប់បំរើក្នុងវិស័យកសិកម្ម ឧស្សាហកម្ម ទេសចរណ៍ សេវាកម្មនានា អភិវឌ្ឍន៍ជនបទ និងការពារបរិដ្ឋានព្រមទាំងសំរាប់បំរើសុខមាលភាពរបស់ប្រជារាស្ត្រទូទៅ ។

២. អភិវឌ្ឍន៍ធនធានធម្មជាតិ និងគ្រប់គ្រងការពារបរិដ្ឋាន ។

៣. គ្រប់គ្រងកិច្ចការវិនិយោគជាតិ និងអន្តរជាតិ ។

**ប្រការ ៥ :** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវរៀបចំរចនាសម្ព័ន្ធរដ្ឋបាល សមាសភាព និងបទបញ្ជាផ្ទៃក្នុង របស់ " គជនា " និង " គជវិ " ដើម្បីអនុវត្តការងារអោយមានប្រសិទ្ធភាព ។ " គជនា " និង " គជវិ " ត្រូវគ្រប់គ្រងដោយអគ្គលេខាធិការរៀងៗខ្លួន ហើយមានសមាជិកជាអ្នកជំនាញការ ។ " គជនា " និង " គជវិ "

មានសិទ្ធិសំរេចលើកិច្ចការធម្មតារបស់ខ្លួន ក្រោមការដឹកនាំប្រចាំថ្ងៃរបស់អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយមានការរួមយោបល់ពីអគ្គលេខាធិការរបស់ក្រុមប្រឹក្សា និងអគ្គលេខាធិការរបស់ " គជនា " និង " ជគវិ " ។ ក្នុងករណីមានបញ្ហាសំខាន់ខុសពីធម្មតា ឬមានការខ្វែងមតិគ្នា អនុប្រធានត្រូវស្នើសុំព្រះរាជតំរិះសំរេចពីសម្តេចក្រុមព្រះ ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**ប្រការ ៦ :** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវមានការប្រជុំចាំបាច់មួយអាទិត្យម្តង ក្រោមអធិបតីភាពនៃប្រធាន ឬអនុប្រធានក្នុងករណីប្រធានមិននៅ ។

**ប្រការ ៧ :** អគ្គលេខាធិការរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អាចមានអ្នកជំនួយការមួយចំនួន ក្នុងករណីដែលចាំបាច់ ។

**ប្រការ ៨ :** ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អាចនឹងអញ្ជើញមន្ត្រីជាន់ខ្ពស់របស់ក្រសួង និងស្ថាប័ននានាដែលគ្មានតំណាងអចិន្ត្រៃយ៍នៅក្នុងក្រុមប្រឹក្សាអោយចូលរួមពិភាក្សា និងសំរបសំរួលការងារវិនិយោគស្ពាននិងអភិវឌ្ឍន៍តាមករណីពាក់ព័ន្ធចាំបាច់ ។

**ប្រការ ៩ :** រាល់អនុក្រឹត្យនិងសេចក្តីសំរេចពីមុន ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ១០ :** រាល់ក្រសួងស្ថាប័នពាក់ព័ន្ធនានា និងក្រុមប្រឹក្សានីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខានេះតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** | ឯកឧត្តម **ហ៊ុន សែន** |